នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: 00២/១៩-0៩-២00៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jun-2014, 13:54
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ការបង្ហាញពីបញ្ហាអង្គច្បាប់ដែលមេធាវីការពារក្ដីលោក ខៀវ សំផន មានបំណងលើកឡើងនៅក្នុងសវនាការបឋមសម្រាប់សំណុំរឿង 00២/0២

---

<u>ដាក់ដោយ៖</u>

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះតុលាការ**សាលាដំបូង

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

កញ្ញា អ៊ូច ស្រីផាត
កញ្ញា សេង លីណា
កញ្ញា Cécile ROUBEIX

**មេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមក្នុងសំណុំរឿង ០០២ ហើយបានកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ ។[1]

២. នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ នៅក្នុងបរិបទនៃការរៀបចំសំណុំរឿង ០០២/០២នេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីដាក់បង្ហាញ ដោយមិនឲ្យហួសពីថ្ងៃច័ន្ទ ទី៩ ខែមិថុនា នូវ *"បញ្ហាអង្គច្បាប់ផ្សេងៗដែលខ្លួនមានបំណងលើកឡើង នៅក្នុងសវនាការបឋម"*។[2]

៣. ថ្ងៃនេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") សូមដាក់ជូនអង្គជំនុំជម្រះនូវបញ្ជីចំណុចអង្គច្បាប់នានា ដែលខ្លួនមានបំណងលើកឡើង ដោយអនុវត្តតាមវិធាន ៨០ ស្ទួន និងវិធាន ៨៩ នៃវិធានផ្ទៃក្នុង។ បញ្ជីនេះមានរៀបរាប់ជាពិសេសនូវការលំបាកផ្នែកគតិយុត្ត ដែលកើតចេញពីសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី E301/9/1 ផង ហើយការតម្រូវឲ្យចាប់ផ្តើមសវនាការសំណុំរឿង ០០២/០២ មុននឹងមានសេចក្តីសម្រេចជាស្ថាពរលើសំណុំរឿង ០០២/០១។[3]

៤. ចំណុចមួយចំនួនត្រូវបានលើកឡើងរួចហើយ នៅក្នុងក្របខណ្ឌនៃការឆ្លើយឆ្លងគ្នាជាលាយលក្ខណ៍អក្សរកន្លងមក តែដោយសារតែវាជារឿងក្តីព្រហ្មទណ្ឌ ដែលតម្រូវឲ្យមានការពិភាក្សាគ្នាដោយផ្ទាល់មាត់ និងជាសាធារណៈ មេធាវីការពារក្តីសូមឲ្យមានការជជែកដេញដោលលើចំណុចដែលខ្លួនយល់ថា អាចជាលក្ខខណ្ឌសម្រាប់ការកាត់ក្តីប្រកបដោយយុត្តិធម៌។

---

[1] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ **E301/9/1** ("សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី **E301/9/1**")

[2] ដីកាបង្គាប់ឲ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ **E305** កថាខណ្ឌទី ១៥។

[3] ពីព្រោះអង្គជំនុំជម្រះបានច្រានចោលសំណើរបស់លោក ខៀវ សំផន ដែលសុំឲ្យរង់ចាំការបញ្ចប់កិច្ចដំណើរការនីតិវិធីនៃបណ្តឹងសាទុក្ខ និងរហូតដល់មានសេចក្តីសម្រេចស្ថាពរលើសំណុំរឿង ០០២/០១ មុននឹងចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ ៖ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង០០២/០១ ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៤ **E301/5/5/1** ។ ការបង្ហាញពីបញ្ហាអង្គច្បាប់ដែលមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងលើកឡើងនៅក្នុងសវនាការបឋម សម្រាប់សំណុំរឿង ០០២/០២

៥. មេធាវីការពារក្តីមានបំណងលើកឡើងដោយផ្ទាល់មាត់ អំពីអំណះអំណាងលើអញ្ញត្រកម្មទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើសការបំពារបំពានធ្ងន់ធ្ងរដល់អនុសញ្ញាក្រុងហ្សឺណែវ និងការដែលអង្គជំនុំជម្រះមិនមានសមត្ថកិច្ចក្នុងការកំណត់ថា ការនិរទេស ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។[4]

៦. ចំពោះបញ្ហាពាក់ព័ន្ធនឹងសាក្សី មេធាវីការពារក្តី មានបំណងលើកឡើងនូវចំណុចដូចតទៅ ៖

- ការជំទាស់ទៅនឹងការស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានប្រយោជន៍សម្រាប់សំណុំរឿង ០០២/០២ វៀរលែងតែមានការបំភ្លឺពីអង្គជំនុំជម្រះ[5]
- ការជំទាស់ទៅនឹងការស្តាប់សក្ខីកម្មអ្នកជំនាញដែលចាត់ទុកថា មានភាពលម្អៀង[6]
- ការពិភាក្សាលើគុណវុឌ្ឍិរបស់សាក្សី ដែលធ្លាប់បានបំពេញការងារ ក្នុងការិយាល័យសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត។

៧. ដោយសារមានភាពស្រពិចស្រពិលលើវិសាលភាពនៃសំណុំរឿង ០០២/០២ និងដោយគិតដល់វាសនានៃបទចោទដែលនៅសេសសល់នោះ មេធាវីការពារក្តីក៏មានបំណងលើកឡើងនូវចំណុចដូចតទៅនេះ ផងដែរ ៖

- ស្នើសុំដល់អង្គជំនុំជម្រះសម្រេចលើវាសនានៃបទចោទដែលនៅសេសសល់ ហើយដែលមិនបានបញ្ចូលទៅក្នុងសំណុំរឿង ០០២/០២[7]

---

[4] សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ **E306/2** ។

[5] សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះការបង្ហាញមុខនៅចំពោះមុខតុលាការនៃមនុស្សមួយចំនួនដែលស្នើឡើងដើម្បីស្តាប់សក្ខីកម្មសម្រាប់សំណុំរឿង ០០២/០២ និងសេចក្តីស្នើសុំការបំភ្លឺទៅលើវិសាលភាពច្បាស់លាស់នៃការពិភាក្សា ដេញដោល បន្ទាប់ពីសេចក្តីសម្រេចនៃនីតិវិធីបំបែកសំណុំរឿងបន្ថែម **E301/9/1** ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤។

[6] ដូចគ្នា ។

[7] សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ **E301/5/2** កថាខណ្ឌទី២៥-២៦ ។ បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម លើសំណុំរឿង ០០២ និងលើការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤ **E301/9/1/1/1** កថាខណ្ឌទី១០ និងទី ២១។ ការបង្ហាញពីបញ្ហាអង្គច្បាប់ដែលមេធាវីការពារក្តីលោក ខៀវ សំផន មានបំណងលើកឡើងនៅក្នុងសវនាការបឋមសម្រាប់សំណុំរឿង ០០២/០២

- ស្នើសុំការបំភ្លឺស្តីពីវិសាលភាពជាក់លាក់នៃសំណុំរឿង ០០២/០២ រួមជាមួយនឹងឧបសម្ព័ន្ធលម្អិតលើចំណុចដែលអង្គជំនុំជម្រះចាត់ទុកថា បានពិនិត្យ និងពិភាក្សាដេញដោលរួចហើយ ដើម្បីអាចគិតទុកមុន និង/ឬ កាត់បន្ថយការជំទាស់ នៅក្នុងពេលពិភាក្សាដេញដោល[8]

៨. ទីបញ្ចប់ ក្នុងករណីដែលសាលក្រមលើសំណុំរឿង ០០២/០១ មិនទាន់ចូលជាស្ថាពរ វាជាការសំខាន់ណាស់ដែលភាគីអាចបន្តពិភាក្សាលើសេចក្តីសន្និដ្ឋានគតិយុត្តិ ដែលមាននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ ក្នុងពេលពិភាក្សាដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០២។ ប្រសិនបើសម្អាងហេតុនៃបណ្តឹងសាទុក្ខទាញចេញមកពីសេចក្តីសន្និដ្ឋាន ក្នុងសាលក្រមរបស់អង្គជំនុំជម្រះ ហើយបើសេចក្តីសន្និដ្ឋាននោះប៉ះពាល់ដល់សំណុំរឿង ០០២/០២ នោះភាគីត្រូវតែមានលទ្ធភាពធ្វើការជំទាស់ ប្រសិនបើសេចក្តីសន្និដ្ឋាននោះត្រូវបានចាត់ទុកថា ទទួលយកបាន សម្រាប់សំណុំរឿង ០០២/០២។ ដូច្នេះ គប្បីពិភាក្សាទៅលើចំណុចដូចតទៅ ៖

- ការបំភ្លឺលើសញ្ញាណនៃ "មូលដ្ឋានគ្រឹះទូទៅ" ដែលអង្គជំនុំជម្រះបានលើកឡើង នៅក្នុងសេចក្តីសម្រេចលេខ E124/7, E131, E302/5 និង E301/9/1[9]
- ការពិភាក្សាដេញដោលលើទម្រង់នៃការជំទាស់ ទាក់ទិននឹងសេចក្តីសន្និដ្ឋានក្នុងសាលក្រមដែលនឹងចេញនាពេលខាងមុខ លើសំណុំរឿង ០០២/០១។

---

[8] សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះការកោះហៅបុគ្គលមួយចំនួនដែលស្នើមកផ្តល់សក្ខីកម្មសម្រាប់សំណុំរឿង ០០២/០២ និងសំណើសុំការបំភ្លឺទៅលើវិសាលភាពជាក់លាក់នៃការពិភាក្សាដេញដោលបន្ទាប់ពីសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង E301/9/1 ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ **E305/9** កថាខណ្ឌទី២៨-៣៤។

[9] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ **E124/7** កថាខណ្ឌទី១០។ ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ **E131** កថាខណ្ឌទី៣។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការបញ្ជាក់បំភ្លឺទាក់ទងនឹងការប្រើប្រាស់ភស្តុតាង និង នីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពី សំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៤ **E302/5** កថាខណ្ឌទី៥ និងទី៧។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២/០២ **E301/9/1** កថាខណ្ឌទី៤២។

៩. មេធាវីការពារក្ដីអាចនឹងស្នើសុំកែប្រែលើបញ្ជីនេះ អាស្រ័យតាមធាតុថ្មីៗដែលអាចនឹងលេចឡើងមុននឹងមានសវនាការបឋម។

១០. **អាស្រ័យហេតុនេះ** មេធាវីការពារក្ដីរបស់ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះមេត្តា ៖

- **យល់ព្រម ទទួលយក**អង្គច្បាប់ផ្សេងៗដែលមេធាវីការពារក្ដីមានបំណងលើកឡើងនេះ
- **អនុញ្ញាតឲ្យមេធាវីការពារក្ដី** លើកឡើងនូវចំណុចទាំងនេះ នៅក្នុងសវនាការបឋមសម្រាប់សំណុំរឿង ០០២/០២។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |